ខែ តុលា ឆ្នាំ២០២១

# សៀវភៅកត់ចំណាំ

## សន្និសីទទូទៅ



**តាមរយៈសន្និសីទទូទៅ ប្អូនៗអាចទទួលបានវិវរណៈផ្ទាល់ខ្លួន !**

សៀវភៅកត់ចំណាំនេះគឺដើម្បីឲ្យប្អូនៗកត់ត្រាទុកនូវគំនិត និងអារម្មណ៍របស់ប្អូនៗអំឡុងសន្និសីទទូទៅ។ កាលប្អូនៗស្ដាប់អ្នកឡើងនិយាយប្រកបដោយការអធិស្ឋាន និងដោយចិត្តស្មោះ នោះព្រះវិញ្ញាណបរិសុទ្ធនឹងថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ( សូមមើល យ៉ូហាន ១៥:២៦ ) ហើយបង្រៀនប្អូនៗអំពី « គ្រប់អ្វីទាំងអស់ដែលអ្នកត្រូវធ្វើ » ( នីហ្វៃទី២ ៣២:៣ )។

# សម័យប្រជុំព្រឹក ថ្ងៃសៅរ៍

« ប្រធានបទទាំងឡាយពុំបានចាត់ទៅឲ្យអ្នកឡើងនិយាយនោះទេ ។ ពួកលោកម្នាក់ៗបានអធិស្ឋានសូមវិវរណៈផ្ទាល់ខ្លួនក្នុងការរៀបចំសារលិខិតរបស់ពួកលោក ។ . . . នៅពេលបងប្អូនសិក្សាប្រធានបទទាំងនោះ សូមរៀននូវអ្វីដែលព្រះអម្ចាស់កំពុងព្យាយាមបង្រៀនដល់ *បងប្អូន* តាមរយៈពួកអ្នកបម្រើរបស់ទ្រង់ » ។

ប្រធាន រ័សុល អិម ណិលសុន[១]

## ចូររក នោះតែងនឹងឃើញ

តើប្អូនៗអាចរកឃើញវត្ថុដែលលាក់ទាំងនេះដែរឬទេ ? ព្រះវិហារបរិសុទ្ធ ១០, ព្រះគម្ពីរ ១១, ស្លាកអ្នកផ្សព្វផ្សាយសាសនា ៣, អ្នកឡើងនិយាយក្នុងសន្និសីទទូទៅ ៤, ព្រះអាទិត្យ ២



តើខ្ញុំមានអារម្មណ៍ថា ព្រះអម្ចាស់កំពុងព្យាយាមបង្រៀនខ្ញុំអំពីអ្វីខ្លះ ?

តើសារលិខិតអ្វីខ្លះដែលលេចធ្លោចំពោះខ្ញុំ ? ហេតុអ្វី ?



តើខ្ញុំនឹងធ្វើអ្វីខ្លះនៅពេលនេះ ? តើខ្ញុំត្រូវបន្តធ្វើអ្វីខ្លះ ?

រចនារូបភាពដោយចសថាលបូត

# សម័យប្រជុំរសៀល
## ថ្ងៃសៅរ៍

តើខ្ញុំមានអារម្មណ៍ថា ខ្ញុំត្រូវធ្វើអ្វីខ្លះ ដើម្បីខិតទៅកាន់តែជិតព្រះអង្គសង្គ្រោះ ?

« ខ្ញុំមានអំណរគុណដែលបងប្អូនមកចូលរួមក្នុងសន្និសីទ [ ទូទៅ ] នេះ ដើម្បីទទួលការបំផុសគំនិតពីស្ថានសួគ៌ ហើយខិតជិតនឹងព្រះវរបិតាសួគ៌ និងព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទរបស់យើង » ។

ប្រធាន ហិនរី ប៊ី អាវរិង[២]



## ល្បែងល្បងប្រាជ្ញា

សូមចាប់ផ្ដើមពីច្រកចូលណាមួយក៏បាន សូមទៅដល់រូបព្រះគម្ពីរនៅចំណុចកណ្ដាល រួចហើយសូមរកផ្លូវត្រឡប់ចេញមកវិញម្ដងទៀត ប៉ុន្តែលើកនេះចេញតាមច្រកផ្សេង ! ច្បាប់មួយទៀត ៖ ប្អូនៗមិនអាចប្រើផ្លូវដដែលពីរដងបានទេ ។

« ខ្ញុំសន្យាថា នៅពេលបងប្អូនស្ដាប់ឮសំឡេងនៃព្រះអម្ចាស់សម្រាប់បងប្អូន នៅក្នុងការបង្រៀននៃសន្និសីទទូទៅនេះ ហើយអនុវត្តតាមការបំផុសគំនិតទាំងនោះ នោះបងប្អូននឹងទទួលអារម្មណ៍ពីការជះឥទ្ធិពលនៃស្ថានសួគ៌ក្នុងជីវិតបងប្អូន ហើយអស់អ្នកដែលនៅជុំវិញបងប្អូននឹងបានទទួលពរ » ។

អែលឌើរ នែល អិល អាន់ឌើរសិន[៣]





តើខ្ញុំត្រូវបានអញ្ជើញឲ្យធ្វើអ្វីខ្លះ ដែលនឹងជួយខ្ញុំឲ្យកាន់តែដូចជាព្រះយេស៊ូវគ្រីស្ទ ? តើខ្ញុំនឹងធ្វើសកម្មភាពតាមការអញ្ជើញនោះដោយរបៀបណា ?





សូមផាត់ពណ៌ឲ្យខ្ញុំ !

# សម័យប្រជុំព្រឹក

## ថ្ងៃអាទិត្យ



តើខ្ញុំបានមានអារម្មណ៍ពីសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះអំឡុង
សម័យប្រជុំនេះដោយរបៀបណា ?

« យើងបានអធិស្ឋាន និងបានអញ្ជើញបងប្អូនឲ្យអធិស្ឋាន ថាព្រះវិញ្ញាណនៃព្រះអម្ចាស់ នឹងគង់នៅនឹងយើងយ៉ាងបរិបូរណ៍ ដើម្បីបងប្អូនអាចស្តាប់ឮសារលិខិត ដែលព្រះអង្គសង្គ្រោះមានជាពិសេសសម្រាប់បងប្អូន— ជាសារលិខិតដែលនឹងនាំភាពសុខសាន្តមកកាន់ព្រលឹងបងប្អូន » ។

ប្រធាន រ័សុល អិម ណិលសុន[៤]

# សម័យប្រជុំរសៀល ថ្ងៃអាទិត្យ

« ប្រសិនបើយើងបង្រៀនដោយព្រះវិញ្ញាណ ហើយបងប្អូនស្ដាប់ដោយព្រះវិញ្ញាណនោះនឹងមានពួកយើងណាម្នាក់និយាយចំស្ថានភាពរបស់បងប្អូន ដែលបញ្ជូនសារលិខិតដ៏ព្យាករផ្ទាល់ខ្លួនសម្រាប់តែបងប្អូនប៉ុណ្ណោះ » ។

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន[៥]

តើខ្ញុំបានទទួលចំណាប់អារម្មណ៍ខាងវិញ្ញាណអ្វីខ្លះ ? តើអ្វីទៅដែលសំខាន់បំផុតសម្រាប់ខ្ញុំនាពេលនេះ ?

## គូររូប

សូមគូររូបគ្រាដែលប្អូនៗចូលចិត្តចេញពីសន្និសីទនៅត្រង់នេះ ! វាអាចជាអ្នកឡើងនិយាយ ដំណើររឿង ឬក៏ចំណាប់អារម្មណ៍ដែលប្អូនៗបានទទួល ។

**កំណត់ចំណាំ**

១. រ័សុល អិម ណិលសុន « Closing Remarks » សន្និសីទទូទៅ ខែ មេសា ឆ្នាំ ២០១៩ ( *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៩ ទំព័រ ១១១ ) ។
២. ហិនរី ប៊ី អាវរិង « Where Two or Three Are Gathered » សន្និសីទទូទៅខែ មេសា ឆ្នាំ ២០១៦ ( *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៦ ទំព័រ ១៩ ) ។
៣. នែល អិល អាន់ឌើរសិន សន្និសីទទូទៅ ខែ តុលា ឆ្នាំ ២០១៧ ( *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ១២៦ ) ។
៤. រ័សុល អិម ណិលសុន « Opening Message » សន្និសីទទូទៅ ខែ មេសា ឆ្នាំ ២០២០ ( *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០២០ ទំព័រ ៧ ) ។
៥. ជេហ្វ្រី អ័រ ហូឡិន សន្និសីទទូទៅ ខែ មេសា ឆ្នាំ ២០១១ ( *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ១១៣ ) ។
៦. នែល អិល អាន់ឌើរសិន សន្និសីទទូទៅ ខែ តុលា ឆ្នាំ ២០១៧ ( *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ១២៥ ) ។

## ការបំផុសគំនិតសម្រាប់ប្អូន។

« មានកំណប់រតនសម្បត្តិមួយនៃការដឹកនាំពីសួគ៌ា ដែលកំពុងរង់ចាំការរកឃើញរបស់បងប្អូននៅក្នុងសារលិខិតនៃសន្និសីទទូទៅ ។ ការសាកល្បងសម្រាប់ពួកយើងម្នាក់ៗគឺស្តីពីរបៀបដែលយើងឆ្លើយតបទៅនឹងអ្វីដែលយើងស្តាប់ឮ អ្វីដែលយើងអាន និងទទួលអារម្មណ៍ » ។

អែលឌើរ នែល អិល អាន់ឌើរសិន[៦]

**ត្រូវការច្បាប់ចម្លងបន្ថែម ?**

សូមទាញយក និងបោះពុម្ពសៀវភៅកត់ចំណាំនេះពីគេហទំព័រ **conference.ChurchofJesusChrist.org** ។

© ២០២១ by Intellectual Reserve, Inc. All rights reserved.

ការអនុញ្ញាតឲ្យបោះពុម្ពកូនសៀវភៅនេះឡើងវិញត្រូវបានអនុញ្ញាតឲ្យតែសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនប៉ុណ្ណោះ មិនមែនសម្រាប់ធ្វើពាណិជ្ជកម្មទេ ។ ការណ៍នេះរួមមានការអនុញ្ញាតសម្រាប់ថ្នាក់ដឹកនាំវួដឲ្យបោះពុម្ពច្បាប់ចម្លងចំនួនតិចតួច សម្រាប់អស់អ្នកដែលពួកគាត់បម្រើនៅក្នុងសមាសភាពនៃការហៅរបស់ពួកគាត់ ។ កូនសៀវភៅនេះត្រូវតែបោះពុម្ពឲ្យបានគ្រប់ទំព័រ ។ ការណ៍នេះមិនរួមបញ្ចូលការអនុញ្ញាតឲ្យបង្ហោះតាមអ៊ីនធឺណិត ប្រើប្រាស់ក្នុងគោលបំណងថ្មី ឬចែកចាយសម្ភារនេះឡើយ ។ ការប្រើប្រាស់សម្ភារនេះលើសពីនេះណាមួយតម្រូវឲ្យមានការអនុញ្ញាត ។

**permissions.ChurchofJesusChrist.org**

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ